# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តរតនគិរី

*សំណុំរឿងព្រហ្មទណ្ឌ*

លេខ : ៧៦

ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨

*សំណុំរឿងជំនុំជម្រះ*

លេខ : ២៤៣

ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៨

*សាលក្រមព្រហ្មទណ្ឌ*

លេខ : ៣៦ "ខ"

ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩

## តា ង នា ម ប្រ ជា រា ស្ត្រ ខ្មែ រ

## សា លា ដំ បូ ង ខេ ត្ត រ ត ន គិ រី

បានបើកសវនាការជាសាធារណៈ នៅសាលសវនាការ នៃសាលាដំបូងខេត្តរតនគិរី
បើកសវនាការនៅ ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ បន្តដល់ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៩
ប្រកាសសាលក្រមនៅ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ២០១៩
ដោយមានសមាសភាពជំនុំជម្រះដូចតទៅ ៖

*ចៅក្រមជំនុំជម្រះ*

| | | | |
|---|---|---|---|
| លោក | [redacted] | ឋានៈអនុប្រធាន | ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| លោក | [redacted] | ឋានៈចៅក្រម | ជាចៅក្រមប្រឹក្សា |
| លោក | [redacted] | ឋានៈចៅក្រម | ជាចៅក្រមប្រឹក្សា |

*តំណាងអយ្យការ*

លោក [redacted] ឋានៈព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តរតនគិរី

*ក្រឡាបញ្ជីសវនាការ*

កញ្ញា [redacted] ឋានៈក្រឡាបញ្ជីសាលាដំបូងខេត្តរតនគិរី

*ដើម្បីជំនុំជម្រះ*

លើសំណុំរឿងព្រហ្មទណ្ឌលេខ ៧៦ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨ ដែលមាន ៖

១-ជនជាប់ចោទឈ្មោះ [redacted] ចំណូល ភេទប្រុស អាយុ២៤ឆ្នាំ ជនជាតិខ្មែរ មុខរបរជាងឈើ កាន់សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ថ្នាក់ទី៧ មានទីកន្លែងកំណើតសង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ មានទីលំនៅមុនពេលឃុំខ្លួននៅ [redacted] ប្រពន្ធឈ្មោះ [redacted] (រ) មានកូនចំនួន១នាក់ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ទោសពីមុន ធ្លាប់ជាប់ពន្ធនាគារ ២ឆ្នាំកន្លះ។ *(ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួន លេខ ១៣៦ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៨)*

២-ជនជាប់ចោទឈ្មោះ [redacted] ផានិត ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ មុខរបរ ជាងឡាន កាន់សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ ថ្នាក់ទី៩ ទីកន្លែងកំណើតនៅភូមិសង្កែ ឃុំស្ពឹងជ័យ ស្រុកជើងព្រៃ ខេត្តកំពង់ចាម មានទី



Scanned with CamScanner

លំនៅមុនពេលឃុំខ្លួន [redacted] នៅលីវ ឪពុកឈ្មោះ [redacted] ( រ) ម្តាយឈ្មោះ [redacted] (រ) ទោសពីមុនគ្មាន។ *(ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួន លេខ ៤៨ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨)*

៣-ជនជាប់ចោទឈ្មោះ [redacted] បុង ហៅ បុង ភេទប្រុស អាយុ២៦ឆ្នាំ ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ កាន់សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ ថ្នាក់ទី៨ ទីកន្លែងកំណើតនៅភូមិអូររមៀត សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី មានទីលំនៅមុនពេលឃុំខ្លួននៅ [redacted] នៅលីវ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ទោសពីមុន គ្មាន។ *(ឃុំខ្លួនតាមសាលក្រមមុនអង្គសេចក្តីលេខ ២៣ "ខ" ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៨)*

៤-ជនជាប់ចោទឈ្មោះ [redacted] វណ្ណៈ ភេទប្រុស អាយុ៣១ឆ្នាំ ជនជាតិខ្មែរ មុខរបរ លក់ដូរ កាន់សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ ថ្នាក់ទី៨ ទីកន្លែងកំណើតនៅភូមិភ្នំស្វាយ សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី មានទីលំនៅបច្ចុប្បន្ននៅ [redacted] ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន០២នាក់ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ទោសពីមុន គ្មាន។ *(ក្រៅឃុំ)*

ជាប់ចោទពីបទ **រក្សាទុក ដឹកជញ្ជូន ឬជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្ទះសំណាក់កាឡាក់ស៊ី០២ ស្ថិតក្នុងភូមិអភិវឌ្ឍន៍ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី កាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៨ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៥-ជនជាប់ចោទឈ្មោះ [redacted] **វិសាល** ភេទប្រុស អាយុ១៩ឆ្នាំ ជនជាតិខ្មែរ មុខរបរសិស្ស កាន់សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ ថ្នាក់ទី១១ មានទីកន្លែងកំណើតភូមិស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ មានទីលំនៅបច្ចុប្បន្ននៅ [redacted] នៅលីវ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ទោសពីមុនគ្មាន ។ *(ក្រៅឃុំ)*

ជាប់ចោទពីបទ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្ទះសំណាក់កាឡាក់ស៊ី០២ ស្ថិតក្នុងភូមិអភិវឌ្ឍន៍ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី កាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៨ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

លោក [redacted] **សារី** ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

-**បានឃើញ** ដីកាដំណោះស្រាយបញ្ជូនរឿងទៅជំនុំជម្រះ លេខ ១៣៦៩/១៨ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៨ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តរតនគិរី។

## អង្គហេតុនៃរឿងមានដូចតទៅ ៖

កាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៨ វេលាម៉ោង ១៨ និង ១០នាទី ស្ថិតនៅភូមិអភិវឌ្ឍន៍ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី មានករណី រក្សាទុក ដឹកជញ្ជូន ឬជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនមួយបានកើតឡើង ដែលប្រព្រឹត្តដោយជនសង្ស័យឈ្មោះ [redacted] ផានិត បានធ្វើសកម្មភាពលក់ថ្នាំញៀន និងត្រូវបាន



Scanned with CamScanner

សមត្ថកិច្ចឃាត់ខ្លួនបាន និងដកហូតបានវត្ថុតាងជាសារធាតុញៀនចំនួន ២ថង់ធំល្មម ដោយប្រើវិធីញុះញ៉ង់ គឺទាក់ទងតាមទូរស័ព្ទឱ្យយកថ្នាំញៀនពីភ្នំពេញមករតនគិរី ហើយមុខសញ្ញាដែលកាន់យកថ្នាំញៀននោះ (ឈ្មោះ [redacted] ផានិត) បានសម្រាកនៅបន្ទប់លេខ ២ (កាឡាក់ស៊ី០២) ត្រូវបានកម្លាំងការិយាល័យជំនាញ ធ្វើការឃាត់ខ្លួនជនសង្ស័យចំនួន ២នាក់ និងសារធាតុញៀនចំនួន២ថង់ធំល្មម។ មន្ត្រីនគរបាលយុត្តិធម៌បានកសាងសំណុំរឿង និងឃាត់ខ្លួនជនសង្ស័យខាងលើ រួមទាំងវត្ថុតាងមកកាន់អយ្យការអមសាលាដំបូងខេត្តដើម្បីចាត់ការតាមនីតិវិធីច្បាប់។

**នាពេលសវនាការ**

-ជនជាប់ចោទឈ្មោះ [redacted] **ចំណូល** ឆ្លើយថា: ខ្ញុំចេះប្រើប្រាស់ថ្នាំញៀនរយៈពេល ១ឆ្នាំហើយ ដោយខ្ញុំជីកឈើដើម្បីកុំឱ្យងងុយដេក។ ខ្ញុំមិនដែលស្គាល់ឈ្មោះ [redacted] ផានិត និងឈ្មោះ [redacted] វិសាល ទេ ហើយក៏មិនដែលលក់ថ្នាំឱ្យគេដែល។ សមត្ថកិច្ចឃាត់ខ្លួន ជាមួយឈ្មោះ [redacted] ផៃយ៉ា ដោយដកហូតបានគ្រឿងញៀនចំនួន ៤00ក្រាម តែមិនមែនឃាត់ខ្លួនជាមួយឈ្មោះ [redacted] ផានិត នោះទេ។ ឈ្មោះ [redacted] វិសាល បានប្រាប់ថា គ្រឿងញៀនទិញពីឈ្មោះនូ មិនមែនឈ្មោះ [redacted] ចំណូល នោះទេ។ ខ្ញុំត្រូវបានតុលាការកាត់ឱ្យជាប់ពន្ធនាគាររយៈពេល ២ឆ្នាំ ៦ខែ។

-ជនជាប់ចោទឈ្មោះ [redacted] **ផានិត** ឆ្លើយថា: ខ្ញុំចេះជក់ថ្នាំតាមមិត្តភក្តិឈ្មោះ រ៉ា ធ្វើជាងឡានជាមួយគ្នា ហើយឈ្មោះ រ៉ា បានណែនាំខ្ញុំឱ្យស្គាល់ឈ្មោះ ដន តាមរយៈទូរស័ព្ទ ហើយឈ្មោះ ដន តែងតែទម្លាក់ថ្នាំឱ្យទៅឈ្មោះ រ៉ា ប្រើជាមួយខ្ញុំពីរទៅបីដង។ បន្ទាប់មកឈ្មោះ ដក បានទាក់ទងខ្ញុំឱ្យជួយយកថ្នាំឱ្យទៅឈ្មោះ ម៉ាន នៅខេត្តរតនគិរី ចំនួន២កញ្ចប់ មិនដឹងទម្ងន់ប៉ុន្មាននោះទេ។ ឈ្មោះ ដន បានផ្ញើសោហ៊ុយឱ្យខ្ញុំចំនួន ២០ម៉ឺនរៀល និងឱ្យថ្នាំខ្ញុំខ្លះ ដើម្បីជក់។ ពេលមកដល់ខេត្តរតនគិរីជាមួយថ្នាំ ២កញ្ចប់ ខ្ញុំក៏ហៅពួកម៉ាកឈ្មោះ **វិសាល** មកជួយឌុបខ្ញុំទៅផ្ទះសំណាក់កាឡាក់ស៊ី ហើយក៏បានហៅឈ្មោះ **ម៉ាន** មកយកថ្នាំ។ ពេលឈ្មោះ **ម៉ាន** មកដល់បានសុំសាកថ្នាំសិនបានឱ្យលុយ ពេលនោះឈ្មោះ [redacted] **វិសាល** ដកថ្នាំបន្តិចដើម្បីឱ្យគេសាក ពេលនោះស្រាប់តែសមត្ថកិច្ចមកទាន់ឃាត់ខ្លួនតែម្តង។

-ជនជាប់ចោទឈ្មោះ [redacted] **បុង** ឆ្លើយថា: ខ្ញុំមិនដែលស្គាល់ឈ្មោះ [redacted] **ផានិត** និងឈ្មោះ [redacted] **ចំណូល** នោះទេ។ ខ្ញុំមិនដែលជួញដូរគ្រឿងញៀនទេ។ ខ្ញុំចេះប្រើប្រាស់គ្រឿងញៀន រយៈពេលជិត ២ឆ្នាំហើយ។ សមត្ថកិច្ចឃាត់ខ្លួន នៅម្តុំព្រលានយន្តហោះ។ សមត្ថកិច្ចឃាត់ខ្លួនមិនបានដកហូតថ្នាំញៀនពីខ្ញុំនោះទេ។ គ្រឿងញៀន គឺប្អូនរបស់ខ្ញុំឈ្មោះ ការ ជាអ្នកទិញ ហើយប្រើជាមួយគ្នា ។

-សាក្សីឈ្មោះ [redacted] ***វិរៈ*** ឆ្លើយថា: កាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៨ វេលាម៉ោង ១៨ និង ១០នាទី ស្ថិតនៅភូមិអភិវឌ្ឍន៍ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី មានករណី **រក្សាទុក ដឹកជញ្ជូន ឬជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** មួយបានកើតឡើង បង្កដោយជនសង្ស័យឈ្មោះ [redacted] **ផានិត** បានធ្វើសកម្មភាពលក់ថ្នាំញៀន និងត្រូវសមត្ថកិច្ចឃាត់ខ្លួនបាន ដោយប្រើវិធានការញុះញ៉ង់ គឺទាក់ទងតាមទូរស័ព្ទឱ្យយកថ្នាំញៀនពីភ្នំពេញមកខេត្តរតនគិរី ហើយមុខសញ្ញាដែលកាន់យកថ្នាំញៀននោះ (ឈ្មោះ [redacted] **ផានិត**) បានសម្រាកនៅបន្ទប់លេខ២ (កាឡាក់ស៊ី២) ត្រូវបានកម្លាំងជំនាញធ្វើការឃាត់ខ្លួនជនសង្ស័យចំនួន២រូបឈ្មោះ [redacted] **ផានិត**



Scanned with CamScanner

និងឈ្មោះ [redacted] **វិសាល** និងដកហូតបានវត្ថុតាងថ្នាំញៀន ចំនួន២៨ង់ធំ ទម្ងន់ ៥១.១១ក្រាម។ ចំពោះឈ្មោះ [redacted] **បុង** ជាមុខសញ្ញានៃការជួញដូរគ្រឿងញៀនផងដែរ។ ម៉្យាងទៀត ជនសង្ស័យភាគច្រើន ឆ្លើយថា ទិញគ្រឿងញៀនពីឈ្មោះ [redacted] **បុង** ហើយឈ្មោះនេះក៏ធ្លាប់ចាប់បានម្តងដែរ តែចោទពីបទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ក៏ត្រូវបានដោះលែងវិញ។ រីឯ ឈ្មោះ [redacted] **ចំណូល** ក៏ត្រូវបានសមត្ថកិច្ចកំណត់មុខសញ្ញាផងដែរ។ នៅថ្ងៃឃាត់ខ្លួនឈ្មោះ [redacted] **ចំណូល** ដកហូតបានថ្នាំញៀនចំនួន១កញ្ចប់ ជាមួយឈ្មោះ [redacted] **អែយ៉ា** បន្ទាប់មកក៏ឈានទៅចាប់ខ្លួនឈ្មោះ [redacted] **ឈៀន** ដកហូតបានថ្នាំញៀនចំនួន១០កញ្ចប់ទៀត និងបានផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ២ឆ្នាំ ៦ខែ ។

-អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **វណ្ណៈ** នៅដំណាក់កាលចៅក្រមស៊ើបសួរៈ នៅថ្ងៃកើតហេតុមិនចាំ ខ្ញុំនៅច្រកព្រំដែនអូរយ៉ាដាវ រកស៊ីលើក និងដឹកឈើ ឱ្យគេ។ ខ្ញុំមិនដែលលក់ថ្នាំឱ្យទៅឈ្មោះ [redacted] **វិសាល** សូម្បីតែម្តង។ ចំពោះ ឈ្មោះ **ចំណូល** ដែលថាយកថ្នាំពីឈ្មោះ **ណាក់** គឺមិនមែនឈ្មោះខ្ញុំទេ។ រីឯ **ឈ្មោះ** [redacted] **ផានិត** ដែលយកថ្នាំមកលក់នៅខេត្តរតនគិរី គឺមិនមែនលក់ឱ្យខ្ញុំទេ។ កាលពីមុនខ្ញុំធ្លាប់ប្រើប្រាស់គ្រឿងញៀនដែរ ហើយសមត្ថកិច្ចបានឃាត់ខ្លួនខ្ញុំកាលពី១ឆ្នាំមុន បន្ទាប់មកតុលាការដោះលែងខញុំវិញ ដោយសារខ្ញុំគ្រាន់តែប្រើប្រាស់ តាំងពីតុលាការដោះលែងខ្ញុំវិញ ខ្ញុំកែខ្លួនមិនដែលប្រើប្រាស់ថ្នាំញៀនទៀតទេ។

-អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **វិសាល** នៅដំណាក់កាលចៅក្រមស៊ើបសួរៈ ខ្ញុំចេះប្រើប្រាស់គ្រឿងញៀនប្រហែលជាង ២ខែ ហើយថ្នាំញៀនដែលប្រើប្រាស់ទិញពីឈ្មោះ ម៉ាន និងពេលខ្លះខ្ញុំទិញពីឈ្មោះ នូភេទប្រុស ,ឈ្មោះ ណាក់ និងឈ្មោះ បុង ម្តងពី ២ម៉ឺនទៅ ៣ម៉ឺនរៀល។ ខ្ញុំពុំធ្លាប់ជួញដូរ ថ្នាំញៀនទេ រាល់ពេលដែលខ្ញុំទិញថ្នាំញៀន គឺសម្រាប់ប្រើប្រាស់ប៉ុណ្ណោះ។ ខ្ញុំពុំដឹងថាឈ្មោះ ផានិត មានថ្នាំញៀនជួញដូរទេ គ្រាន់តែដឹងថាគាត់ចេះប្រើប្រាស់ថ្នាំញៀនដែរ។ ពេលសមត្ថកិច្ចឃាត់ខ្លួន ខ្ញុំពុំដឹងថា ឈ្មោះ ផានិត មានថ្នាំញៀនច្រើនប៉ុណ្ណាទេ។

-អំណានកំណត់ហេតុស្តីពីការសួរតទល់រវាងឈ្មោះ [redacted] **វណ្ណៈ** និងឈ្មោះ [redacted] **ផានិត** នៅដំណាក់កាលចៅក្រមស៊ើបសួរៈ ឈ្មោះ [redacted] **វណ្ណៈ** មិនស្គាល់ឈ្មោះ [redacted] **ផានិត** នោះទេ ហើយឈ្មោះ [redacted] **ផានិត** ក៏មិនដែលស្គាល់ឈ្មោះ [redacted] **វណ្ណៈ** នោះដែរ។

-អំណានកំណត់ហេតុស្តីពីការសួរតទល់រវាងឈ្មោះ [redacted] **វណ្ណៈ** និងឈ្មោះ [redacted] **វិសាល** នៅដំណាក់កាលចៅក្រមស៊ើបសួរៈ ឈ្មោះ [redacted] **វណ្ណៈ** ស្គាល់ឈ្មោះ [redacted] **វិសាល** ព្រោះធ្លាប់ឃើញរៀននៅសាលារៀនគ្រូយើង។ ចំណែកឈ្មោះ [redacted] **វិសាល** ឆ្លើយថា ស្គាល់ឈ្មោះ [redacted] **វណ្ណៈ** ព្រោះជាអ្នកលក់នំ ក្នុងសាលារៀនគ្រូយើង ហើយចំពោះគ្រឿងញៀនដែលទិញពីឈ្មោះ ណាក់ មិនមែនជាឈ្មោះ [redacted] **វណ្ណៈ** នៅចំពោះមុខនេះទេ ហើយក៏មិនដែលលក់ថ្នាំឱ្យខ្ញុំដែរ។

-អំណានលទ្ធផលកោសលវិច័យគ្រឿងញៀន លេខ ១៤៧៣៨/១៨ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៨ របស់អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ឃើញមានវត្ថុមានសារធាតុ

ញៀនឈ្មោះ មេតំហ្វេតាមីន បរិមាណធាតុគិតជាភាគរយនៃទម្ងន់គឺ ៦៧.១៦% ដែលស្ថិតនៅក្នុងតារាងទី២ មាត្រា ៥ ចំណាត់ថ្នាក់គ្រឿងញៀន ។

-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា: ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទហើយ បញ្ជាក់បានថា កាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៨ ស្ថិតនៅភូមិអភិវឌ្ឍន៍ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី ពិតជាមានករណី រក្សាទុក ដឹកជញ្ជូន ឬជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន។ ដូច្នេះ តំណាងអយ្យការស្នើសុំតម្កល់បទចោទប្រកាន់ដូចមានក្នុងដីកាសន្និដ្ឋានស្ពាពរ លេខ ៦០៦ អក/១៨ ចុះថ្ងៃទី ០២ ខែវិច្ឆិកា ឆ្នាំ២០១៨ ទុកនៅដដែល ។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានការពារ: ដោយកូនក្តីរបស់ខ្ញុំបាទ បានសារភាពផងដែរ ម៉្យាងទៀត ដោយសារការអូសទាញពីមិត្តភក្តិ ខ្វះការអប់រំ មិនមានការពិចារណាត្រឹមត្រូវ ទើបធ្លាក់ខ្លួនប្រព្រឹត្តបទល្មើសបែបនេះ។ ដូច្នេះ ស្នើសុំប្រធានក្រុមប្រឹក្សាមេត្តាផ្តល់នូវគោលការណ៍មនុស្សធម៌ដល់កូនក្តីរបស់ខ្ញុំបាទផង ហើយកូនក្តីរបស់ខ្ញុំក៏បានជាប់ពន្ធនាគារទទួលបានការអប់រំ កែប្រែបានមួយចំនួនផងដែរ។

-ជនជាប់ចោទឈ្មោះ [redacted] ចំណូល និយាយសំដីចុងក្រោយថា: ស្នើសុំជួយរកយុត្តិធម៌ដល់ខ្ញុំបាទផង ។

-ជនជាប់ចោទឈ្មោះ [redacted] ផានិត និយាយសំដីចុងក្រោយថា: ស្នើសុំបន្ធូរបន្ថយទោស ។

-ជនជាប់ចោទឈ្មោះ [redacted] ប៊ុង និយាយសំដីចុងក្រោយថា: ស្នើសុំជួយរកយុត្តិធម៌ដល់ខ្ញុំបាទផង ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ ។

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] វិសាល និងឈ្មោះ [redacted] វណ្ណៈ។

-ក្រោយពីបានស្តាប់ចម្លើយសាក្សីជាមន្រ្តីនគរបាលយុត្តិធម៌ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារជនជាប់ចោទ ។

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ ។

-ក្រោយពីបានពិនិត្យភស្តុតាងជាឯកសារ និងកំណត់ហេតុផ្សេងៗ ។

-ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

## សាលាដំបូងខេត្តរតនគិរី
## យល់ឃើញថា

១/ តាមដីកាដំណោះស្រាយបញ្ជូនរឿងទៅជំនុំជម្រះលេខ ១៣៦៩/១៨ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៨ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តរតនគិរី សម្រេចបញ្ជូនសំណុំរឿងមកជំនុំជម្រះ ដែលមានជនជាប់ចោទឈ្មោះ [redacted] **ចំណូល** , [redacted] **ផានិត** , [redacted] **វណ្ណៈ** និង [redacted] **ប៊ុង** ពីបទ **រក្សាទុក ដឹកជញ្ជូន ឬជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** តាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងឈ្មោះ



Scanned with CamScanner

[redacted] វិសាល ពីបទ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២/ តាមរបាយការណ៍សំយោគ លេខ ៩៧/១៨ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៨ បានសន្និដ្ឋានថា កាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៨ ស្ថិតនៅភូមិអភិវឌ្ឍន៍ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី មានករណីរក្សាទុក ដឹកជញ្ជូន ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន មួយកើតឡើង ដែលបង្កឡើងដោយឈ្មោះ [redacted] ផានិត , [redacted] ចំណូល (នូ) , [redacted] វណ្ណៈ (ណាក់) , [redacted] បុង (បុង) , ដន និងឈ្មោះ [redacted] វិសាល ។

៣/ តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ផានិត បានឱ្យដឹងថា នៅថ្ងៃកើតហេតុខ្លួន បានយកថ្នាំពីឈ្មោះ ដន នៅភ្នំពេញ ចំនួន២កញ្ចប់ធំ ទម្ងន់ ៥១.១១ក្រាម មកផ្ទះសំណាក់កាឡាក់ស៊ី២ នៅខេត្តរតនគិរី ដើម្បីយកឱ្យឈ្មោះ ម៉ាន ។ ពេលមកដល់ខ្លួនបានហៅឈ្មោះ [redacted] វិសាល ឱ្យជួយខុបខ្លួនទៅផ្ទះសំណាក់នោះ ។

៤/ តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] វិសាល បានឱ្យដឹងថា ខ្លួនទិញគ្រឿងញៀនមកប្រើប្រាស់ប៉ុណ្ណោះមិនបានលក់ចែកចាយនោះទេ ហើយគ្រឿងញៀនទិញពីឈ្មោះ ម៉ាន, នូ, ណាក់ និង បុង ម្តងពី ២ម៉ឺនទៅ ៣ម៉ឺនរៀល ។

៥/ តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ចំណូល និងឈ្មោះ [redacted] បុង បានបដិសេធថា ពួកខ្លួនមិនធ្លាប់បានលក់គ្រឿងញៀនឱ្យឈ្មោះ [redacted] វិសាល នោះមិនអាចឱ្យតុលាការជឿជាក់បានឡើយ។ ដោយហេតុថាតាមចម្លើយរបស់ឈ្មោះ [redacted] វិសាល បានបញ្ជាក់ថា ខ្លួនទិញពីឈ្មោះ បុង និងឈ្មោះ នូ ហើយតាមលទ្ធផលនៃការស្រាវជ្រាវរបស់សមត្ថកិច្ចក៏បានកំណត់ថា ឈ្មោះ បុង ([redacted] បុង) និងឈ្មោះ នូ ([redacted] ចំណូល) មានសារតារជាតិគ្រប់គ្រាន់ ។ ម្យ៉ាងទៀត តាមចម្លើយរបស់មន្ត្រីនគរបាលយុត្តិធម៌ ក៏បានបញ្ជាក់ផងដែរថា ឈ្មោះ [redacted] ចំណូល និងឈ្មោះ [redacted] បុង ជាមុខសញ្ញានៃការជួញដូរគ្រឿងញៀននៅក្នុងខេត្តដែរ ខាងសមត្ថកិច្ចកំណត់មុខសញ្ញាតាមចាប់យូរហើយ។

៦/ តាមចម្លើយរបស់ឈ្មោះ [redacted] វណ្ណៈ បានឱ្យដឹងថា ខ្លួនមិនដែលយកគ្រឿងញៀន ឬរកស៊ីលក់គ្រឿងញៀនជាមួយឈ្មោះ [redacted] ផានិត និងឈ្មោះ [redacted] វិសាល នោះទេ។ ម្យ៉ាងទៀត តាមកំណត់ហេតុសួរតទល់រវាងឈ្មោះ [redacted] វណ្ណៈ ,ឈ្មោះ [redacted] ផានិត និងឈ្មោះ [redacted] វិសាល បានបញ្ជាក់ថា ពួកគេមិនបានស្គាល់គ្នានោះទេ ហើយក៏មិនដែលបានទិញគ្រឿងញៀនពីឈ្មោះ [redacted] វណ្ណៈ នេះដែរ។ គ្រាន់តែទិញពីឈ្មោះ ណាក់ តែមិនមែនឈ្មោះ [redacted] វណ្ណៈ ដែលនៅចំពោះមុខទេ។ ដូច្នេះ បញ្ជាក់បានឈ្មោះ [redacted] វណ្ណៈ មិនមានពាក់ព័ន្ធនឹងករណីគ្រឿងញៀនក្នុងសំណុំរឿងព្រហ្មទណ្ឌនេះទេ ព្រោះគ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់នោះទេ។ ដូច្នេះ គប្បីតុលាការសម្រេចឱ្យរួចខ្លួនពីបទចោទ ។

៧/ ផ្អែកតាមរបាយការណ៍របស់សមត្ថកិច្ច, ចម្លើយរបស់ជនជាប់ចោទ និងភស្តុតាងនានាក្នុងសំណុំរឿងអាចឱ្យតុលាការជឿបានថា នៅថ្ងៃកើតហេតុជនជាប់ចោទឈ្មោះ សាន ផានិត ពិតជាបានយកគ្រឿងញៀនពី



Scanned with CamScanner

ឈ្មោះ ម៉ាន មកខេត្តរតនគិរី លក់ឱ្យឈ្មោះ ម៉ាន ហើយជនជាប់ចោទឈ្មោះ [redacted] វិសាល ជាអ្នកឧបទៅ និងជនជាប់ចោទឈ្មោះ [redacted] ចំណូល និងឈ្មោះ [redacted] ប៊ុង ជាអ្នកលក់គ្រឿងញៀនឱ្យឈ្មោះ [redacted] វិសាល ។ ដូច្នេះ អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ផានិត ,ឈ្មោះ [redacted] ចំណូល និងឈ្មោះ [redacted] ប៊ុង ត្រូវនឹងធាតុផ្សំបទល្មើស **រក្សាទុក ដឹកជញ្ជូន ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ។ ចំណែក អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **វិសាល** ត្រូវនឹងធាតុផ្សំបទល្មើស **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ។

៨/ តាមលទ្ធផលកោសលវិច័យលេខ ១៤៧៣៨/១៨ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៨ អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ឃើញមានវត្ថុមានសារធាតុញៀនឈ្មោះ **មេតំហ្វេតាមីន** បរិមាណធាតុគិតជាភាគរយនៃទម្ងន់គឺ $៦៧.១៦\% = \frac{៦៧.១៦ \times ៥១.១១}{១០០} =$ ៣៤.៣២ក្រាម ។ ចំណុចនេះបញ្ជាក់ពីពិរុទ្ធភាពរបស់ជនជាប់ចោទ តាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៥ ចំណុចទី៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៩/ សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ បានចោទប្រកាន់ជនជាប់ចោទឈ្មោះ [redacted] ចំណូល ,ឈ្មោះ [redacted] ផានិត ,ឈ្មោះ [redacted] វណ្ណៈ និងឈ្មោះ [redacted] ប៊ុង ពីបទ **រក្សាទុក ដឹកជញ្ជូន ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ដោយតម្កល់បទចោទទុកនៅដដែលនោះ តុលាការយល់ឃើញថាជនជាប់ចោទឈ្មោះ [redacted] **វណ្ណៈ** មិនមានពាក់ព័ន្ធនឹងបទល្មើសនេះទេ គប្បីឱ្យរួចផុតពីបទចោទ។ ចំណែកឯ ជនជាប់ចោទឈ្មោះ [redacted] ចំណូល ,ឈ្មោះ [redacted] ផានិត និងឈ្មោះ [redacted] ប៊ុង មានលក្ខណៈត្រឹមត្រូវ។ រីឯ ជនជាប់ចោទឈ្មោះ [redacted] វិសាល ចោទប្រកាន់ពីបទ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ហើយសុំតម្កល់បទចោទប្រកាន់នេះទុកដដែលតាមដីកាសន្និដ្ឋានស្ថាពរនោះ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ តុលាការ នឹងពិចារណា។

១០/ សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានស្នើសុំឱ្យតុលាការបន្ធូរបន្ថយទោស ដោយលើកឡើងថា ខ្វះការអប់រំ គ្មានការពិចារណា ទើបធ្លាក់ខ្លួនប្រព្រឹត្តបទល្មើស។ តុលាការយល់ឃើញថា ដោយសារតែជនជាប់ចោទជាមុខសញ្ញានៃការជួញដូរ ដែលសមត្ថកិច្ចបានកំណត់មុខសញ្ញាយូរហើយ ម្យ៉ាងទៀតជនជាប់ចោទក៏មានសំណុំរឿងច្រើននៅតុលាការដែលបានសម្រេច និងមិនទាន់សម្រេចសេចក្តីផងដែរ។

១១/ ជនជាប់ចោទឈ្មោះ [redacted] ចំណូល ,ឈ្មោះ [redacted] ផានិត ,ឈ្មោះ [redacted] ប៊ុង និងឈ្មោះ [redacted] វិសាល មានសតិសម្បជញ្ញៈ និងសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌនូវទង្វើរបស់ខ្លួន ។

១២/ គ្មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **វណ្ណៈ** ពីបទ **រក្សាទុក ដឹកជញ្ជូន ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិអភិវឌ្ឍន៍ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី កាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៨ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៤០ កថាខណ្ឌ៥ ចំណុច៦** និងមាត្រា **៤៥** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១៣/ មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ចំណូល ,ឈ្មោះ [redacted] ផានិត និងឈ្មោះ [redacted] ប៊ុង ពីបទ **រក្សាទុក ដឹកជញ្ជូន ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅ



Scanned with CamScanner

ភូមិអភិវឌ្ឍន៍ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី កាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៨ **បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៥ ចំណុច៦ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន**។

**១៤/** មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើ ជនជាប់ចោទឈ្មោះ [redacted] **វិសាល ពីបទ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិអភិវឌ្ឍន៍ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី កាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៨ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**១៥/** អំពើដែលជនជាប់ចោទឈ្មោះ [redacted] ចំណូល ,ឈ្មោះ [redacted] **ផានិត**,ឈ្មោះ [redacted] **ប៊ុង** និងឈ្មោះ [redacted] **វិសាល** បានប្រព្រឹត្ត គឺធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ និងសន្តិសុខសង្គម ជាពិសេសធ្វើឱ្យប៉ះពាល់ដល់សុខភាពរបស់អ្នកដទៃ និងអាចបង្កឱ្យមានសង្គមអសន្តិសុខបាន។ ម្យ៉ាងទៀត ចំនួនគ្រឿងញៀនមានច្រើន ហើយជនជាប់ចោទជាមុខសញ្ញានៃការជួញដូរក្នុងខេត្តរតនគិរី និងជាប់មានសំណុំរឿងច្រើននៅតុលាការដូច្នេះទណ្ឌកម្ម ដែលត្រូវអនុវត្តលើជនជាប់ចោទនីមួយៗ តុលាការនឹងពិនិត្យពិចារណា។

**១៦/** វត្ថុតាងដែលដកហូតពីជនជាប់ចោទឈ្មោះ [redacted] **ផានិត** រួមមាន ម៉ៅ្យសត្ថា ដាក់ក្នុងស្រោមសំបុត្របិទជិត សង្ស័យសារធាតុញៀន ទម្ងន់ ៥១.១១ ក្រាម ទាំងថង់ ជាវត្ថុខុសច្បាប់ គប្បីរឹបអូសបំផ្លាញចោល។ ចំណែកលុយខ្មែរ ចំនួន ៣០,០០០ (បីម៉ឺន) រៀល ,ទូរស័ព្ទចំនួន២គ្រឿង គឺម៉ាក NOKIA Nចុចពិល ចំនួន១គ្រឿង និងម៉ាក IPHONE 5 (ខូច) ចំនួន១គ្រឿង ជាវត្ថុប្រព្រឹត្តបទល្មើស គប្បីរឹបអូសជាសម្បត្តិរដ្ឋ។ រីឯ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ចំនួន១ និងកាបូបដៃ ចំនួន១ មិនមានពាក់ព័ន្ធនឹងបទល្មើស គប្បីប្រគល់ឱ្យសាមីខ្លួនវិញ ។

**១៧/** ជនជាប់ចោទឈ្មោះ [redacted] វណ្ណៈ ត្រូវបានចៅក្រមស៊ើបសួរសម្រេចមិនឃុំខ្លួនតាមដីកាសម្រេចលេខ ១០៩០/១៨ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៨ ។

**១៨/** ជនជាប់ចោទឈ្មោះ [redacted] វិសាល ត្រូវបានចៅក្រមស៊ើបសួរសម្រេចមិនឃុំខ្លួនតាមដីកាសម្រេចលេខ ៣៦១ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨ ។

## <u>**ហេតុដូច្នេះសម្រេច**</u>

១. ឱ្យឈ្មោះ [redacted] **វណ្ណៈ** ភេទប្រុស អាយុ៣៣ឆ្នាំ (សាវតារជាតិដូចខាងលើ) ***<u>រួចខ្លួនពីបទចោទ</u>*** ពីបទ **រក្សាទុក ដឹកជញ្ជូន ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិអភិវឌ្ឍន៍ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី កាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៨ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៥ ចំណុច៦ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងបញ្ញត្តិមាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**២.** ផ្តន្ទាទោសដាក់ពន្ធនាគារ៖



Scanned with CamScanner

ក-ឈ្មោះ [redacted] ចំណូល ហៅ ណូ ឬ នូ ភេទប្រុស អាយុ២៤ឆ្នាំ (សាវតារជាតិដូចខាងលើ)

ខ-ឈ្មោះ [redacted] ផាន់និត ភេទប្រុស អាយុ១៩ឆ្នាំ (សាវតារជាតិដូចខាងលើ)

គ-ឈ្មោះ [redacted] មុខ ហៅ មុខ ភេទប្រុស អាយុ២៦ឆ្នាំ (សាវតារជាតិដូចខាងលើ)

កំណត់ក្នុងម្នាក់ៗរយៈពេល *__៨ (ប្រាំបី) ឆ្នាំ__* ពីបទ *រក្សាទុក ដឹកជញ្ជូន ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន* ប្រព្រឹត្តនៅភូមិអភិវឌ្ឍន៍ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី កាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៨ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិ *មាត្រា ៤០ កថាខណ្ឌ៥ ចំណុច៦ និងមាត្រា ៤៥* នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

ឃ-ឈ្មោះ [redacted] ទិសាល ភេទប្រុស អាយុ១៩ឆ្នាំ (សាវតារជាតិដូចខាងលើ) កំណត់រយៈពេល *__៣ (បី) ខែ__*

ពីបទ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិអភិវឌ្ឍន៍ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី កាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៨ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣. វត្ថុតាងរួមមាន៖

-*រឹបអូសបំផ្លាញចោល* នូវម៉្សៅសថ្លា ដាក់ក្នុងស្រោមសំបុត្របិទជិត សង្ស័យសារធាតុញៀន ទម្ងន់ ៥១.១១ ក្រាម ទាំងថង់ ។

-*រឹបអូសជាសម្បត្តិរដ្ឋ* នូវលុយខ្មែរ ចំនួន ៣០,០០០ (បីម៉ឺន) រៀល ,ទូរស័ព្ទចំនួន២គ្រឿង គឺម៉ាក NOKIA Nចុចពិល ចំនួន១គ្រឿង និងម៉ាក IPHONE 5 (ខូច) ចំនួន១គ្រឿង ។

-*ប្រគល់ឱ្យទៅម្ចាស់ដើមវិញ* នូវ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ចំនួន១ និងកាបូបដៃ ចំនួន១ ។

៤. សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទទាំងបួននាក់ និងកំបាំងមុខចំពោះជនជាប់ចោទឈ្មោះ [redacted] *វិសាល* និងឈ្មោះ [redacted] *វណ្ណៈ* ។

-ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់ ។

| | | | |
|---|---|---|---|
| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សា** |
| **ហត្ថលេខា និងត្រា** | **ហត្ថលេខា និងត្រា** | **ហត្ថលេខា និងត្រា** | **ហត្ថលេខា និងត្រា** |
| **ហាន់ មុយលីន** | **សេង ស៊ឹមសុរិយា** | **គង់ តាំងម៉េង** | **ឈុន ច័ន្ទសីហា** |

---

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម។

ថ្ងៃ ព្រហស្បតិ៍ ១រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រតនគិរី, ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner